**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កំណត់ហេតុ</u>

**ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុន អេមិណិន ហ្គាម៉ិន(ខេមបូឌា) លីមីធីត**

ឆ្នាំពីរពាន់ម្ភៃ ខែមេសា ថ្ងៃទី ១៨មានការបើកកិច្ចប្រជុំនៅក្រុមហ៊ុន អេមិណិនហ្គាម៉ិន(ខេមបូឌា)លីមីធីត ដែលមានទីតាំងស្ថិតនៅ ផ្លូវលេខ ២១ ភូមិ ព្រៃកថ្មី ឃុំ ទឹកវិល ស្រុក ស្អាង ខេត្ត កណ្ដាល។

ក្រោមអធិបតីភាពលោក PENG HAO JUN ជានាយកក្រុមហ៊ុន និងលោកស្រី ឈុន អ៊ី ប្រធានផ្នែករដ្ឋបាលបានពិនិត្យឃើញអំពីបញ្ហាក្រុមហ៊ុនជួបវិបត្តិខ្វះខាតការនាំចូលវត្ថុធាតុដើម គ្មានអ្នកបញ្ជាទិញ និងមិនមានទីផ្សារនាំចេញ ដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ COVID-19 ដូច្នេះហើយទើបក្រុមហ៊ុនឈានទៅដល់ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៤៧៣ នាក់ ៤០៦ ស្រី នាក់ ប្រុស ៦៧ នាក់។

## <u>សមាសភាពចូលរួម</u>

<u>-តំណាងនិយោជក</u>

-លោក PENG HAO JUN នាយកក្រុមហ៊ុន

-លោកស្រី ឈុន អ៊ី ប្រធានផ្នែករដ្ឋបាល

<u>-តំណាងកម្មករនិយោជិត</u>

-លោកស្រី វ៉ាប់ មិថុនា ប្រធានសហជីព កម្ពុជា-អាស៊ាន នៃក្រុមហ៊ុនអេមិណិនហ្គាម៉ិន (ខេមបូឌា)លីមីធីត

-លោក តុល រដ្ឋាជាអនុប្រធានសហជីពកម្ពុជា-អាស៊ាននៃ ក្រុមហ៊ុនអេមិណិនហ្គាម៉ិន(ខេមបូឌា)លីមីធីត

-លោកស្រី ស្រេង វ៉ាន់នី ជាលេខាធិការ សហជីពកម្ពុជា-អាស៊ាននៃក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា)លីមីធីត

លោកស្រី វ៉ាប់មិថុនាប្រធានសហជីព កម្ពុជា-អាស៊ាន នៃក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា)លីមីធីត មានប្រសាសន៍ថា ក្រុមហ៊ុន ពិតជាគ្មានការងារធ្វើមែន ព្រោះគ្មានអ្នកបញ្ជាទិញ ដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ COVID-19 ដូច្នេះនាងខ្ញុំមិនជំទាស់ការព្យួរកិច្ចសន្យាការងារនេះទេ។

-លោកស្រី ពន្លក ស្រីអ៊ុម ជាតំណាងកម្មករ នៃក្រុមហ៊ុនអេមិណិន ហ្គាម៉ិន(ខេមបូឌា)លីមីធីត មាន ប្រសាសន៍ថា ថ្មីៗនេះក្រុមហ៊ុន ពិតជាជួបបញ្ហាវិបត្តិ ហិរញ្ញវត្ថុនិង ផលិតផលមិនអាចនាំចេញបាន ដោយសារ ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ COVID-19 ដូច្នេះនាងខ្ញុំឯកភាពលើការព្យួរកិច្ចសន្យាការងារនេះ ព្រោះក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន។

-ប្រធានក្រុមគ្រប់ផ្នែកទាំងអស់បានចូលរួមកិច្ចប្រជុំ ហើយបានឯកភាពទាំងអស់គ្នារួចផ្ដិតមេដៃទុកជាភស្តុតាង។

-លទ្ធផលពិភាក្សា

-លោក PENG HAO JUN នាយកក្រុមហ៊ុន តំណាងកម្មករ និងប្រធានសហជីពមូលដ្ឋានបានឯកភាពគ្នាលើការព្យួរកិច្ចសន្យាការងារនេះ ព្រោះក្រុមហ៊ុនពិតជាជួបវិបត្តិខ្វះខាតការនាំចូលវត្ថុធាតុដើម គ្មានអ្នកបញ្ជាទិញ និងមិនមានទីផ្សារនាំចេញបាន ពិតជាគ្មានការងារធ្វើមែន។

-ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន ៣០ ដុល្លារអាមេរិកក្នុង១ខែសម្រាប់កម្មករនិយោជិតម្នាក់។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១៥និង៣០នាទីល្ងាច ថ្ងៃខែឆ្នាំដដែល។

នាយកក្រុមហ៊ុន អេមិណិន ហ្គាមិ៉ន (ខេមបូឌា)លីមីធីត

PENG HAO JUN

ថ្ងៃសៅរ៍ ១១រោច ខែ ចេត្រ ឆ្នាំ ជូត ឯកស័ក ព.ស២៥៦៤

ធ្វើនៅ កណ្តាល,ថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០២០

ស្នាមមេដៃតំណាងកម្មករនិងសហជីព

១-វ៉ាប់ មិថុន ២-តុលរដ្ឋា

៣-ពន្លក ស្រីអ៊ីម ៤-ណុប ស៊ីនឿន

៥-ទ្រី ចាន់ឌីម ៦-ឆេង សុធានី

៧-រុំ សៀកនី ៨-ខុម ស្រីភ័ស្ត

៩-អេង ម៉ារ៉ា ១០-ហ៊ាង ស្រីនាង

១១-វ៉ាន់ សុខវ៉ា ១២-ហ៊ន ចន្ទី

១៣-នៅ យ៉ន ១៤-ឡេ្យា សំអុល